**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

******

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៥.០៧០/០៨ គ.ជ.ប.អគ្គ.៣ស**

ភ្នំពេញ ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៨

# គ.ជ.ប បិទវគ្គបណ្តុះបណ្តាលស្តីពីការឃោសនាបោះឆ្នោត

វគ្គបណ្តុះបណ្តាលដល់មន្ត្រីគណៈកម្មការខេត្ត ក្រុង រៀបចំការបោះឆ្នោត(គខ/កប) តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ស្តីពីការឃោសនាបោះឆ្នោត ដែលបានប្រព្រឹត្តទៅអស់រយៈពេល ២ ថ្ងៃ បានបញ្ចប់នៅរសៀលថ្ងៃទី ៩ ខែ ឧសភា ឆ្នាំ ២០០៨ ក្រោមអធិបតីភាពឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប ។

ឯកឧត្តម អ៊ឹម សួស្តី បានធ្វើការផ្តាំផ្ញើនៅក្នុងពិធីបិទវគ្គនោះថា គខ/កប ត្រូវពង្រឹងសមត្ថភាពការងាររបស់ខ្លួនជាប្រចាំ និងធ្វើកិច្ចសហការគ្នាទៅវិញទៅមកឱ្យបានល្អ ជាពិសេសត្រូវចេះរៀបចំមេរៀនឱ្យបានត្រឹមត្រូវ នៅពេលដែលត្រូវទៅបង្រៀនដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ/សប) ។ ឯកឧត្តមបានសង្កត់ធ្ងន់ថា គខ/កប ទាំងអស់ត្រូវរក្សាជំហរអព្យាក្រឹត នៅក្នុងការអនុវត្តការងាររបស់ខ្លួន ដោយឈរលើមូលដ្ឋានច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធី ។

ឯកឧត្តមបានណែនាំថា គខ/កប ត្រូវរៀបចំផែនការប្រជុំជាប់ប្រចាំជាមួយគណៈបញ្ជាការឯកភាពខេត្ត ក្រុង តំណាងគណបក្សនយោបាយ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្លាស់ប្តូរយោបល់គ្នា និងទប់ស្កាត់នូវទំនាស់ ។ ហើយនៅពេលខាងមុខនេះ គឃ/សប នឹងត្រូវបានជ្រើសរើស ដូច្នេះ គខ/កប ត្រូវណែនាំបន្តឱ្យមានកិច្ចប្រជុំជាប្រចាំនៅថ្នាក់ គឃ/សប ផងដែរ ។

នៅក្នុងពិធីបិទវគ្គនោះដែរ ឯកឧត្តម អ៊ឹម សួស្តី បានធ្វើការបកស្រាយនូវសំណួរជាច្រើន ដែលទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត និងលទ្ធផលនៃការបោះឆ្នោត ។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះ មានសិក្ខាកាមចូលរួមសរុបចំនួន ១១០ នាក់ ក្នុងនោះមន្ត្រីមកពី គខ/កប ទាំង ២៤ មានចំនួន ៧២ នាក់ (១ ខេត្ត ក្រុងចំនួន ៣ នាក់) តំណាងគណបក្សនយោបាយចំនួន ១៧ នាក់ មកពីគណបក្សនយោបាយចំនួន ៩ (គណបក្សប្រជាជនកម្ពុជា គណបក្សសម រង្ស៊ី គណបក្សហ៊្វុនស៊ិនប៉ិច គណបក្សហង្សដារ៉ាចលនាប្រជាធិបតេយ្យ គណបក្សសិទ្ធិមនុស្ស គណបក្សខ្មែរសាធារណរដ្ឋ គណបក្សខ្មែរឈប់ក្រ គណបក្សនរោត្តម រណឫទ្ធិ និងគណបក្សប្រជាធិបតេយ្យខ្មែរ) និងតំណាងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២១ នាក់ មកពីអង្គការចំនួន ១៣ (អង្គការ CWLHRD អង្គការ COMFREL អង្គការ BDO អង្គការ CSD អង្គការ YCC អង្គការ CDRI អង្គការ CCDV អង្គការ LDOMP អង្គការ MLNV អង្គការអភិវឌ្ឍន៍ធនធានមនុស្ស អង្គការអភិវឌ្ឍន៍កសិកម្ម-ឧស្សាហកម្ម អង្គការពន្លឺអនាគតស្ត្រី FLOW និងសមាគមអតីតអ្នកបំរើជាតិ ) ។

BtmanbEnmsmTnakTngTrsBe l x³ 023 214 374 / 012 855 018 E-mail: necinfo@forum.org.kh, Web-site : www.necelect.org.kh